គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា

# ព្រឹត្តិបត្រព័ត៌មាន

លេខ ១៦

Gakugei 東京学芸大学 Tokyo Gakugei University

Supported by 日本財団 THE NIPPON FOUNDATION

SHCC

ចេញផ្សាយ៖ ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹង ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

## វគ្គបណ្តុះបណ្តាលសុខភាពសិក្សាលើកទី ១៥





វគ្គបណ្តុះបណ្តាលសុខភាពលើកសិក្សាលើកទី១៥ ធ្វើឡើងចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ នៅសណ្ឋាគារពូលូវ៉ៃ រាជធានីភ្នំពេញ។

នៅថ្ងៃដំបូងនៃវគ្គបណ្តុះបណ្តាលនេះគឺជា ថ្ងៃបញ្ចប់នៃការបណ្តុះបណ្តាលសុខភាពសិក្សាកម្រិតបឋមសិក្សា។ វគ្គបណ្តុះបណ្តាលបន្ទាប់នឹងផ្តោតកាន់តែស៊ីជម្រៅលើជំនាញវិជ្ជាជីវៈសម្រាប់សុខភាពសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង។

នៅខាងដើមវគ្គបណ្តុះបណ្តាល សាស្ត្រាចារ្យបណ្ឌិត អាសាគីរ៉ា តាកាស៊ី ប្រធានគម្រោង SHCC បានធ្វើបទបង្ហាញអំពីប្រវត្តិគម្រោងចាប់តាំងពីឆ្នាំ ២០២០ មកទល់បច្ចុប្បន្ន។ ដូចសព្វមួយដងនឹងវគ្គបណ្តុះបណ្តាលកន្លងមកនេះ ថ្នាក់និទស្សន៍ត្រូវបានធ្វើឡើងដោយគ្រូឧទ្ទេសសុខភាពសិក្សាចំនួន ២នាក់។ យើងបានអញ្ជើញ នំពពក (Nom PoPok) ដែលជាអង្គការផ្តោតលើការអប់រំអាហារូបត្ថម្ភដោយមានការរៀបចំផែនការសិក្សាដោយប្រើប្រាស់ល្បែងអប់រំពីអាហារូបត្ថម្ភហៅថា«ការីតា(Karuta)»។

## ការឆ្លុះបញ្ចាំងលើវគ្គបណ្តុះបណ្តាល SHCC ឆ្នាំ ២០២៣

UENO Marie

លោកសាស្ត្រាចារ្យ អាសាគីរ៉ា បានធ្វើបទបង្ហាញអំពីការឆ្លុះបញ្ចាំងពីការបណ្តុះបណ្តាលគម្រោង SHCC សម្រាប់ឆ្នាំ ២០២៣។ នៅក្នុងបទបង្ហាញ គាត់បានបង្ហាញរូបភាពជាច្រើននៃក្រុម SHCC មុន និងក្រោយពេល COVID-19 ដោយបានចោតជាសំណួរថា «តើមានអ្វីផ្លាស់ប្តូរនៅក្នុងក្រុមរបស់យើងបើប្រៀបធៀបនឹងពេលដែលទើបចាប់ផ្តើម?» អ្នកចូលរួមទាំងអស់ បានសង្កេតឃើញថាមានការផ្លាស់ប្តូរទឹកមុខនៅក្នុងកិច្ចប្រជុំអនឡាញ កាន់តែមានភាពធូរស្រាល និងចាប់ផ្តើមមានស្នាមញញឹមបន្តិចម្តងៗ ហើយទីបំផុតយើងអាចជួបផ្ទាល់នៅកម្ពុជាក្នុងវគ្គបណ្តុះបណ្តាល។ លោកសាស្ត្រាចារ្យបានបញ្ជាក់ផងដែរថា យើងកាន់តែមានភាពស្និទស្នាលពីមួយវគ្គទៅមួយវគ្គ ក្នុងបរិយាកាសដែលអ្នករាល់គ្នាមានអារម្មណ៍ធូរស្រាល និងរីករាយក្នុងការសិក្សា។ ទាំងនេះជាចំណុចសំខាន់សម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាព។



លោកសាស្ត្រាចារ្យ អាសាគីរ៉ា បានផ្តល់ប្រធានបទចំនួន ២ សម្រាប់ការពិភាក្សាជាក្រុមដូចខាងក្រោម។ គ្រូឧទ្ទេសបានចូលរួមក្នុងការពិភាក្សាលើប្រធានបទទាំងនេះ

១) តើត្រូវមានគុណភាព និងសមត្ថភាពអ្វីខ្លះដើម្បីក្លាយជាគ្រូល្អ?

២) តើលក្ខខណ្ឌអ្វីខ្លះដែលរួមចំណែកដល់សុខុមាលភាព និងសុភមង្គលរបស់គ្រូ?

លោកសាស្ត្រាចារ្យគ្រោងនឹងពិភាក្សាលើប្រធានបទគុណសម្បត្តិ និងសីលធម៌របស់គ្រូល្អក្នុងវគ្គបណ្តុះបណ្តាលបន្ទាប់។




*ការប្រជុំតាមអនឡាញមានសភាពព្រួយបារម្មណ៍បន្តិច*



*មានស្នាមញញឹមនៅវគ្គបណ្តុះបណ្តាលផ្ទាល់*



## ថ្នាក់និទស្សន៍
## —យន្តការ និងមុខងារនៃរាងកាយមនុស្ស
## —ការផ្លាស់ប្តូររាងកាយ និងផ្លូវចិត្តអំឡុងពេលវ័យជំទង់

UENO Marie



នៅក្នុងវគ្គបណ្តុះបណ្តាលលើកទី១៥ គ្រូឧទ្ទេសនៃវិទ្យាស្ថានទាំងពីរ បានធ្វើថ្នាក់និទ្សសន៍ស្តីពីជំពូកទី ២ «យន្តការ និងមុខងារនៃរាងកាយមនុស្ស» ដោយអ្នកគ្រូ សាន ស្រីរី និងថ្នាក់និទស្សន៍ដោយអ្នកគ្រូ នូវ សុផល លើជំពូកទី១១ ស្តីពី «ការផ្លាស់ប្តូររាងកាយ និងផ្លូវចិត្តអំឡុងពេលវ័យជំទង់» រួមទាំងដាក់បញ្ចូលសកម្មភាពជាក្រុមមួយចំនួនក្នុងអំឡុងបង្រៀនដែលអនុញ្ញាតឱ្យអ្នកចូលរួមបញ្ចេញគំនិតរបស់ពួកគេ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា។



លោកសាស្ត្រាចារ្យបានផ្តល់នូវមតិត្រឡប់ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការពិចារណាពីមូលហេតុ និងសារៈសំខាន់នៃការបញ្ចូលសកម្មភាពជាក្រុម។ ខណៈពេលដែលសកម្មភាពជាក្រុមអាចរីករាយសម្រាប់សិស្ស។ ប៉ុន្តែវាអាចនឹងគ្មានប្រសិទ្ធភាពក្នុងការរៀនសូត្ររបស់សិស្សឱ្យស៊ីជម្រៅ បើគ្មានយុទ្ធសាស្ត្រច្បាស់លាស់ ។ ដូច្នេះនៅពេលប្រើសកម្មភាពជាក្រុមនៅក្នុងការបង្រៀន វាចាំបាច់ណាស់ក្នុងការរៀបចំផែនការដោយប្រុងប្រយ័ត្នអំពីរបៀបប្រើប្រាស់ ដើម្បីលើកទឹកចិត្តដល់ការចូលរួម និងការរៀនសូត្ររបស់សិស្សឱ្យមានអត្ថន័យ។



អ្នកអាចយកផ្នែកខ្លះនៃសរីរាង្គពីគំរូកាយវិភាគសាស្ត្ររបស់មនុស្ស។
សិស្សអាចរៀន និងចងចាំសរីរាង្គនីមួយៗបានដោយការប៉ះ!

## ល្បែងអប់រំចំណីអាហារ ការីតា (KARUTA )

MASUKO Yuuka

យើងបានអញ្ជើញ នំពពក(Nom PoPok) ដែលក្រុមហ៊ុនផ្តោតលើការអប់រំចំណីអាហារ ជាគ្រូឧទ្ទេសក្នុងការពន្យល់អំពី ល្បែងអប់រំចំណីអាហារ ការីតា (Food Education Karuta)។ ល្បែងអប់រំចំណីអាហារ ការីតា (Food Education Karuta)គឺជាឧបករណ៍បង្រៀនដែលអាចឱ្យកុមាររៀនអំពីការទទួលទានអាហារត្រឹមត្រូវ និងអាហារូបត្ថម្ភតាមរយៈការលេង។ យើងមានសកម្មភាពគិតអំពីមេរៀនដោយប្រើប្រាស់ល្បែងអប់រំចំណីអាហារ ការីតា។ យើងមិនមែនជាកុមារ ប៉ុន្តែគ្រូឧទ្ទេសសុខភាពសិក្សាទាំងអស់ចូលចិត្តលេងល្បែងការីតានេះ។ យើងបានរកឃើញថាវាជាសម្ភារៈជំនួយមួយដ៏ល្អសម្រាប់ការបង្រៀនអាហារូបត្ថម្ភនៅវិទ្យាស្ថានគរុកោសល្យ។ នៅចុងបញ្ចប់នៃវគ្គ នំពពក(Nom PoPok) បានផ្តល់អំណោយដ៏អស្ចារ្យមួយដល់ពួកយើងនូវនំសុខភាព ដែលប្រើប្រាស់ផ្លែឈើ និងបន្លែក្នុងស្រុកជាគ្រឿងផ្សំដែលសំបូរទៅដោយអាហារូបត្ថម្ភ។ វាជាពេលវេលាដែលពោរពេញដោយភាពរីករាយ និងរំភើបសូម្បីតែក្នុងចំណោមគ្រូឧទ្ទេស។





# ការសម្តែងរឿងស្តីពីបញ្ហាសុខភាព

MASUKO Yuuka

នៅថ្ងៃទី ៣ នៃវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី ១៥ ការសរសេរការសន្ទនារបស់តួអង្គសម្រាប់សម្តែងដោយគ្រូឧទ្ទេសបានអនុញ្ញាតឱ្យក្រុមនីមួយៗបង្ហាញការសម្តែងយ៉ាងរលូន។ ករណីសិក្សានេះផ្តល់នូវវិធីសាស្ត្រជាក់ស្តែងបន្ថែមទៀតនៃការសិក្សាអំពីបញ្ហាសុខភាពសិក្សាក្នុងវ័យជំទង់ និងការស្វែងរកដំណោះស្រាយសម្រាប់ពួកគេ។ គ្រូឧទ្ទេសមានភាពប៉ិនប្រសព្វក្នុងការសម្តែងក៏ដូចជាការសរសេរការសន្ទនារបស់តួអង្គ។

នៅក្នុងវគ្គបណ្តុះបណ្តាល SHCC ពេលខ្លះ ការសម្តែងសាច់រឿង (Role Play) ត្រូវបានអនុវត្តន៍។ គោលបំណងនៃការសម្តែងគឺមិនមែនដើម្បីធ្វើសកម្មភាពគួរឱ្យចាប់អារម្មណ៍នោះទេ ប៉ុន្តែដើម្បីដឹងថាតើការបង្កើតគ្រោងការនៃរឿងមានដំណោះស្រាយបែបណាឆ្លើយតបទៅនឹងបញ្ហា។ យ៉ាងណាមិញ ជំនាញនៃការសម្តែងរបស់គ្រូឧទ្ទេសគឺល្អឥតខ្ចោះ ហើយពេលខ្លះធ្វើឱ្យទស្សនិកជនផ្ទុះសំណើចថែមទៀតផង។

**ករណីនៃការសម្តែង៖**

ក. ការបោកប្រាស់តាមបណ្តាញទំនាក់ទំនងសង្គម

ខ. ការបៀតបៀនសិស្សស្រី

គ. អ្នកប្តូរយេនឌ័រ

ឃ.គ្រូបង្រៀនប្រើអំពើហឹង្សា









## ករណី ក « ការបោកប្រាស់តាមបណ្តាញទំនាក់ទំនងសង្គម »

- សិស្សប្រុសថ្នាក់ទី៧ម្នាក់ កំពុងតែសប្បាយចិត្ត ហើយភ្លេចធ្វើកិច្ចការផ្ទះ ព្រោះតែគាត់ទើបតែមានមិត្តស្រី ដោយស្គាល់គ្នាតាមរយៈបណ្តាញសង្គម ប៉ុន្តែគាត់មិនធ្លាប់បានជួបគ្នានៅឡើយទេ។
- ថ្ងៃមួយ មិត្តស្រីបានសុំខ្ចីលុយពីគាត់ដោយហេតុផលថាម្តាយនាងមានជំងឺ ត្រូវការប្រាក់។ ដូច្នេះហើយ គាត់បានកុហកឪពុកម្តាយថាយកលុយសម្រាប់ប្រើប្រាស់ក្នុងការសិក្សា រួចហើយក៏បានផ្ញើឱ្យនាងតាម ABA។
- ក្រោយពីផ្ញើលុយរួច នាងមិនអាចទាក់ទងបានទៀតទេ។
- ម្តាយគាត់បារម្ភ ហើយបានប្រាប់គ្រូរបស់គាត់ពីរឿងនេះថាគាត់ត្រូវបានគេបោកប្រាស់។

## ករណី ខ « ការបៀតបៀនសិស្សស្រី »







## ករណី គ «អ្នកប្តូរយេនឌ័រ»



## ករណី ឃ « គ្រូបង្រៀនប្រើអំពើហឹង្សា »





គ្រប់ករណីទាំងអស់គឺទាក់ទងនឹងបញ្ហាសុខភាព ដែលអាចអនុញ្ញាតឱ្យគ្រូឧទ្ទេសអាចអនុវត្តវិធីសាស្ត្រនេះនៅក្នុងថ្នាក់សុខភាពសិក្សាផ្ទាល់ខ្លួន ដើម្បីឱ្យគរុនិស្សិតស្វែងយល់អំពីករណីសក្តានុពលជាច្រើននៅក្នុងប្រទេសកម្ពុជា។

# ពិធីប្រគល់រង្វាន់ SHCC និងពិធីជប់លៀង

គម្រោង SHCC បានប្រារព្វពិធីជួបជុំបំណាច់ឆ្នាំ និងពិធីជប់លៀងការចូលនិវត្តន៍សម្រាប់នាយកនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ឯកឧត្តម ប៊ិន ធុំ នៅសណ្ឋាគារ CHECK inn BKK ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី១៥។ នៅពេលល្ងាចនេះបានចាប់ផ្តើមជាមួយនឹងការផ្តល់កិត្តិយសដល់គ្រូឧទ្ទេសចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងប្រគល់វិញ្ញាបនបត្រ និងពានរង្វាន់ SHCC សម្រាប់ឆ្នាំ ២០២៣។ ការរំលេចនៃព្រឹត្តិការណ៍នេះគឺការលាគ្នាដោយស្មោះស្ម័គ្រចំពោះនាយកជាទីស្រឡាញ់របស់យើង ឯកឧត្តម ប៊ិន ធុំ ។ វាគឺជាការជួបជុំដែលមិនអាចបំភ្លេចបានដែលពោរពេញទៅដោយការដឹងគុណ និងការជូនពរដ៏កក់ក្តៅ ដោយអបអរសាទរទាំងភាពជោគជ័យនៃការបណ្តុះបណ្តាល និងការដឹកនាំដ៏ពិសេសរបស់នាយក។



*ពិធីការនីដ៏អស្ចារ្យ*




*ពានរង្វាន់ SHCC ត្រូវបានប្រគល់ជូនគ្រូឧទ្ទេសទាំងអស់ ដោយបានផ្តល់កាបូបតូចមួយសម្រាប់ដបទឹករបស់គម្រោងSHCC។*



*ពានរង្វាន់អ្នកចូលរួមវគ្គបណ្តុះបណ្តាលពេញលេញសម្រាប់គ្រូឧទ្ទេសទាំង ៧ នាក់!! ដូច្នេះហើយ SHCC បានផ្តល់រង្វាន់លើកទឹកចិត្តជា LCD Projector សម្រាប់ការប្រើប្រាស់សម្រាប់ការបង្រៀនមុខវិជ្ជាសុខភាពសិក្សា ដោយសារតែគ្រូឧទ្ទេសនៅ BTEC មានចំនួន ៤នាក់!!*



*ការជូនពរពីគ្រូឧទ្ទេសនៃ BTEC*



*ការច្រៀងជាក្រុមពីគ្រូឧទ្ទេសនៃ PTEC*



*ការរាំរបាំជប៉ុនដោយសមាជិកគម្រោង SHCC*



***ទំនាក់ទំនងដ៏រឹងមាំរវាង BTEC និង PTEC***

យើងបានចំណាយពេលវេលាសប្បាយជាច្រើនជាមួយគ្នាក្នុងពិធីជប់លៀងនេះ។ BTEC PTEC និង គម្រោង SHCC បានរៀបចំការសម្តែងជូនលោកនាយក ប៊ិន ធុំ ដើម្បីអបអរសាទរការចូលនិវត្តន៍របស់គាត់។
យើងអាចពង្រឹងទំនាក់ទំនងមួយនេះមកទល់ពេលនេះ។សូមជួយសហការធ្វើឱ្យ SHCC កាន់តែឆ្ពោះទៅមុខបន្ថែមទៀត!!

សូមអរគុណសម្រាប់ការគាំទ្រ ដល់គម្រោង SHCC!!

យើងគោរពស្រលាញ់ លោកនាយក ប៊ិន ធុំ

ក្រុម SHCC ជារៀងរហូត!!



*ពោរពេញដោយក្តីស្រឡាញ់នៅក្នុងចំណោមសមាជិក SHCC ទាំងអស់*

School Health Development Project for All Cambodian Children

# Newsletter

Vol. 16

Gakugei 東京学芸大学 Tokyo Gakugei University

Supported by THE NIPPON FOUNDATION

SHCC

Issued: February 21st, 2024

## *15th School Health Training at Poulo Wai Hotel*

The 15th School Health Training was held from December 25 to 27 at the Poulo Wai Hotel in Phnom Penh.

The first day of the training marked the end of the basic school health training for primary school courses. The next training will be more professional for school health in lower secondary courses for Phnom Penh Teacher Education College (PTEC) and Battambang Teacher Education College (BTEC).

At the beginning of the training, Prof. Dr. Asakura Takashi, project leader of SHCC presented about the project's history since 2020. As for the training so far, trial lessons were conducted by 2 lectures from School Health lecturers. We welcomed Nom PoPok, an organization focused on nutrition education, they had a lesson planning activity using a food education game called "Karuta".





## *Reflection on SHCC training 2023*

UENO Marie

Prof. Asakura presented the reflection of the SHCC training for 2023. In his presentation, he showed several pictures of the SHCC team before and after COVID-19 and asked, 'What has changed in our team compared it just started?' All participants realized that our faces in zoom meetings are gradually becoming more relaxed and smiling, and finally, we were able to meet in person in Cambodia for training. Dr. Asakura explained that as we have more training, we become closer to each other in a comfortable environment where everybody feels relaxed and happy to study. This is actually an important point for effective learning.

Dr. Asakura also provided us with two topics for group discussions as follows. All lecturers participated in these discussions.
1) What qualities and competencies are required to be a good teacher?
2) What conditions contribute to a teacher's well-being and happiness?
Dr. Asakura is planning to discuss the qualities and morals of a good teacher in the next training.






*A bit nervous at online meeting*



*Smile in physical training*



## Trial Lesson

## —Mechanism and function of human body

## —Physical and mental changes during adolescence

UENO Marie





In the 15th SHCC training, School Health lectuers delivered the trial lessons. Ms. Sreyry taught Chapter 2, 'Mechanism and Function of the Human Body,' while Ms. Sophal covered Chapter 11, 'Physical and Mental Changes during Adolescence.' Both lectures also introduced some group activities during the lessons allowing participants to express their ideas and closely work together.

The professors also gave feedback by emphasizing the importance of considering the reasons and significance of incorporating group activities. While group activities can be enjoyable for students. However, they may not effectively deepen students' learning without a clear strategy. Therefore, when applying group activities in teaching, it is essential to carefully plan how to utilize them to encourage meaningful student engagement and learning.



You can take some of the organs' parts from the human body's anatomical model. Students can learn and remember each organs by touching them!

## Food education Karuta Games

MASUKO Yuuka

We invited Nom PoPok, who runs a food education company, as a lecturer to explain about Food Education Karuta. Food Education Karuta is a teaching tool that enables children to learn about proper food intake and nutrition through play. We had an activity to think about a lesson using a Food Education Karuta. We are not children, but all of the School Health lecturers enjoyed playing with Karuta. We also found that it is a great material for teaching nutrition at the Teacher Education College.

At the end of the lecture, Nom PoPok gave us a great gift of healthy sweets using local fruits and vegetables as nutritious ingredients. It was a fun-filled and excited time even among the lecturers.







# *Role Play on Health Problems*

MASUKO Yuuka

On Day 3 of the 15th School Health lecture training, the Role Play script created by the lecturers allowed each group to demonstrate the play smoothly. The case studies provide a more practical way of learning about School Health problems in adolescence and finding solutions for them. Lecturers have excellent acting skills as well as script writing.

In SHCC training, sometimes Role Play was applied. The aim of Role Play is not to act interestingly, but to see what kind of solution scenario we have created in response to the problems. Nevertheless, the acting skills of the instructors were excellent and the audience sometimes burst into laughter.

**The cases of the role play:**

A. Social networking romance scams

B. Bullying of female students

C. Transgender

D. Violent teachers.





## Case A "Social networking romance scams"

- A Grade 7 male student is now happy and forgets doing homework because he just got a new girlfriend he met through SNS, but he never met her once.
- One day, the girlfriend asked to borrow his money and she said it was for her mother's illness, so he lied to his parents to get the money and sent it to her via ABA.
- After sending the money, she could not be contacted anymore.
- His worried mother noticed and told his teacher that he had been defrauded.





## Case B "Bullying of female students"







## Case C "Transgender"



## Case D "Violent teachers"





All the cases are related to health problems, lecturers can apply them in their own School Health classes for the student teachers to learn about many potential cases in Cambodia.

# SHCC Award Ceremony and Farewell Party

SHCC held the Reunion and Farewell party for H.E. Mr. Bin Chhom, Director of Battambang Teacher Education College at CHECK Inn Hotel BKK, following the completion of the 15th SHCC training.

The evening began with a ceremony to honor the training participants and present certificates and SHCC awards for 2023. The highlight of the event was a heartfelt farewell to our dearest director, H.E. Mr. Bin Chhom. It was a memorable gathering filled with gratitude and warm wishes, celebrating both the training's success and our director's exceptional leadership.



*Wonderful MC*




*SHCC award was presented to all lecturers by giving a small bag for SHCC tumbler.*



*Perfect Attendance Award for 7 lecturers!! SHCC presented the LCD Projector as an incentive award for use in teaching Health classes to the BTEC team because 4 lecturers awarded it.*



*Blessing from BTEC lecturers*



*A chorus from PTEC lecturers*



*Japanese Traditional Dance by SHCC Teams*



*Strong bond between BTEC and PTEC*

We had a lot of fun time together at a party. BTEC, PTEC and SHCC office prepared performances for H.E. Mr. Bin Chhom to celebrate his retirement.

We have been able to strengthen our relationship. Let's make SHCC move forward more and more!!

Thank you so much for supporting SHCC!!

We love and respect you!

Team SHCC Forever!!



Full of LOVE in all SHCC members

SHCC

School Health for all Cambodian Children